# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី

## អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន២

កាលពីម្សិលមិញ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣ ជូនទៅសហចៅក្រមស៊ើបអង្កេត ជាប្រយោជន៍ដើម្បីឲ្យកិច្ចស៊ើបសួរទៅលើអំពើឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងនោះអាចនឹងបើកដំណើរការទៅបាន ។ ការដាក់ជូននេះ ត្រូវបានធ្វើឡើងដោយស្របទៅតាមសាលដីការបស់អង្គបុរេជំនុំជម្រះ នៅក្នុងការពិចារណារបស់ខ្លួនពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារវាង សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង (ការខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ) ដែលសហព្រះរាជអាជ្ញា បានទទួលនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ។

តាមច្បាប់ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាឯកសារសម្ងាត់ ។ យ៉ាងនេះក៏ដោយ ការទទួលស្គាល់អំពីសារៈសំខាន់នៃកិច្ចការរបស់អង្គជំនុំជម្រះនេះ និងការចាំបាច់សម្រាប់សាធារណជនដែលត្រូវទទួលបាននូវព័ត៌មានស្តីពីការជឿនលឿននៃដំណើរការនីតិវិធី វិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ផ្តល់ជូនដល់សាធារណជននូវព័ត៌មានសង្ខេបដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងនេះ ដោយគិតពិចារណាអំពីបូរណភាពនៃការស៊ើបសួរ, អត្តសញ្ញាណនៃជនរងគ្រោះ និងសាក្សី ហើយនិងអំពីសច្ចធារណ៍នៃនិរទោសរបស់ជនសង្ស័យ ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣ មានឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តឡើងដែលជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ដោយបង្កើតបានជាការបដិសេធន៍មួយដែលមានលក្ខណៈជាប្រព័ន្ធ និងដោយខុសច្បាប់ទៅលើសិទ្ធិរបស់ប្រជាជនកម្ពុជា និងកំណត់បាននូវជនសង្ស័យសរុបចំនួនប្រាំ (៥) រូប ។

ដោយមានមូលដ្ឋាននៅលើការស៊ើបអង្កេតបឋមមួយ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីទី២ បានស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើស្ថានភាពនៃអង្គហេតុផ្សេងៗគ្នាចំនួនប្រាំបី(០៨) ស្តីពីការធ្វើមនុស្សឃាត, ការធ្វើទារុណកម្ម, ការឃុំខ្លួនដោយខុសច្បាប់, ការធ្វើពលកម្មដោយបង្ខំ និង ការធ្វើទុក្ខបុកម្នេញ ។ ការចោទប្រកាន់នានាទៅតាមអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ បើសក្ខីកម្មត្រូវបានបង្ហាញ នឹងបង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំង

មនុស្សជាតិ, អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣ បានស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើស្ថានភាពនៃអង្គហេតុផ្សេងៗគ្នាចំនួនសាមសិបពីរ (៣២) ស្តីពីការធ្វើមនុស្សឃាត, ការធ្វើទារុណកម្ម, ការឃុំខ្លួនដោយខុសច្បាប់, ការធ្វើពលកម្មដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញ ។ ការចោទប្រកាន់នានាទៅតាមអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣ បើសក្តីកម្មត្រូវបានបង្ហាញ នឹងបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និង អំពើប្រល័យពូជសាសន៍ ។

នៅ អ.វ.ត.ក នេះ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ពុំមានផែនការណាមួយដើម្បីចាត់វិធានការធ្វើការស៊ើបអង្កេតបឋមក្រោយៗទៀតបន្ថែមទៅលើជនសង្ស័យផ្សេងៗទៀតនោះឡើយ ។ តាមរយៈការបញ្ជូនជនសង្ស័យចំនួនប្រាំ (៥) រូបនេះឲ្យទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបំពេញកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី មានការយល់ស្របតាមសេចក្តីថ្លែងការណ៍របស់អតីតសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ ដែលថាសំណុំរឿងចុងក្រោយ ដែលត្រូវធ្វើការចោទប្រកាន់ទាំងនេះនឹងនាំមកនូវការទទួលខុសត្រូវកាន់តែទូលំទូលាយថែមទៀតចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥-១៩៧៩ ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩